ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣១៩ ប្រ.ក. កសក

# ប្រកាស
# ស្តីពី
# ការកំណត់ប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើនេសាទ ក្នុងដែននេសាទសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១០ ស្តីពីនីតិវិធីនៃការវិនិយោគ ការដេញថ្លៃជាសាធារណៈ ឬការជួលតាមការព្រមព្រៀងនិងការបង់ថ្លៃឈ្នួលនេសាទ
- បានឃើញលិខិតលេខ២៨៥ ស.ជ.ណ.កស ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

# សម្រេច

**ប្រការ១ .-**

ប្រកាសនេះ កំណត់អំពីប្រភេទឧបករណ៍នេសាទគ្រួសារ ឧបករណ៍នេសាទសិប្បកម្ម និងឧបករណ៍នេសាទឧស្សាហកម្ម ដែលអនុញ្ញាតឱ្យធ្វើនេសាទក្នុងដែននេសាទសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២ .-**

ប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើនេសាទក្នុងដែននេសាទសមុទ្រ ដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ ត្រូវអនុវត្តតាមចំនួន ទំហំ ប្រវែង និងរដូវកាល។ ចំពោះប្រភេទឧបករណ៍នេសាទដែលមានប្រសិទ្ធភាពសមាមាត្រទៅនឹងកម្លាំងសេះនៃមធ្យោបាយអូសទាញ ដែលមិនមែនជាប្រភេទម៉ាស៊ីនទូក កាណូតត្រូវគណនាសម្រាប់យកថ្លៃឈ្នួលដែននេសាទស្មើ៥០%។

ប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើនេសាទក្នុងដែននេសាទសមុទ្រ ត្រូវបានកំណត់ក្នុងតារាងឧបសម្ព័ន្ធដែលភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចធ្វើការកែសម្រួល ឬកំណត់បន្ថែមនូវប្រភេទឧបករណ៍នេសាទដែលពុំមានចែងក្នុងប្រកាសនេះ ដោយផ្អែកតាមព័ត៌មាននៃការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រនិងតាមការចាំបាច់។

**ប្រការ៤ .-**

ជនណាដែលធ្វើនេសាទដោយប្រើប្រាស់ឧបករណ៍នេសាទដែលហាមឃាត់ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ៥ .-**

ប្រកាសលេខ៦៣០ ប្រក.កសក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកំណត់ប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើនេសាទក្នុងដែននេសាទទឹកសាបនិងដែននេសាទសមុទ្រនៃព្រះរាជាណាចក្រកម្ពុជានិងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធ

ភ្ជាប់ប្រកាសលេខ ៣១៩ ប្រក កសក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០១៥

ស្តីពី " ការកំណត់ប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើនេសាទក្នុងដែននេសាទសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា "

### ១-ឧបករណ៍នេសាទគ្រួសារ

| ល.រ | ឈ្មោះ ឧបករណ៍នេសាទ | ចំនួន | ប្រវែង(ម៉ែត្រ) | ក្រឡា | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ឈិបរុញដោយដៃ | | | | |
| ២ | ឈ្នាងអូសក្រែងឈាមដោយដៃ | | | ២ស.មឡើង | |
| ៣ | ឈ្នក់ក្តាម | ១០០ឈ្នក់ | | | |
| ៤ | ថ្នងដងគី | | | | |
| ៥ | ធ្នាក់មឹកសំបកខ្យង | ១.៥០០ខ្យង | | | |
| ៦ | ប៉ុក | | | | |
| ៧ | ផ្ទុងផាង | | | | |
| ៨ | មងក្តាម | | ២.០០០ម | ៦ស.មឡើង | |
| ៩ | មងត្រីកាតាំង | | ២.០០០ម | ៦ស.មឡើង | |
| ១០ | មងត្រីក្បក | | ២.០០០ម | ៣,៥ស.មឡើង | |
| ១១ | មងត្រីកាម៉ុង | | ២.០០០ម | ៤ស.មឡើង | |
| ១២ | មងត្រីការ៉ាវ | | ២.០០០ម | ៧ស.មឡើង | |
| ១៣ | មងត្រីបេកា | | ២.០០០ម | ៨ស.មឡើង | |
| ១៤ | មងត្រីស | | ២.០០០ម | ២ស.មឡើង | |
| ១៥ | មងត្រីផ្ទោង | | ២.០០០ម | ២,៥ស.មឡើង | |
| ១៦ | មងបង្គា៣ជាន់ | | ២.០០០ម | ៣,៨ស.មឡើង | |
| ១៧ | មងបង្គា១ជាន់ | | ២.០០០ម | ៣,៥ស.មឡើង | |
| ១៨ | មងហ៊ុម | | ៥០០ម | ៣ស.មឡើង | |
| ១៩ | លបក្តាម | ៥០០លប | | ៦ស.មឡើង | |
| ២០ | លបខ្យង | ១០០លប | | | |
| ២១ | លបត្រី | ៣០លប | | | |
| ២២ | លបមឹក | ១០០លប | | ៤ស.មឡើង | |
| ២៣ | សន្ទូចបបែល | ១.៥០០ផ្លែ | | | |
| ២៤ | សន្ទូចរនង | ១.៥០០ផ្លែ | | | |
| ២៥ | សាង | | | | |
| ២៦ | សំណាញ់ | | | | |
| ២៧ | ស្ទ | | | | |
| ២៨ | អញ្ចង | | | | |
| ២៩ | អួនខូវ ( មងខូវ ) | | ២០០ម | ៣ស.មឡើង | |
| ៣០ | អួនហ៊ុមកៀនច្រាំង (អួនហ៊ុមតាមឆ្នេរ) | | ២០០ម | ៣ស.មឡើង | |

## ២-ឧបករណ៍នេសាទសិប្បកម្ម

| ល.រ | ឈ្មោះ ឧបករណ៍នេសាទ | ចំនួន | ប្រវែង(ម៉ែត្រ) | ក្រឡា | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ឈ្នក់ក្តាម | លើសពី១០០ឈ្នក់ | | | |
| ២ | ឈ្នាងអូសក្រែងឈាម | | មិនលើសពី១ម | ២ស.មឡើង | |
| ៣ | ឈ្នាងអូសគ្រំក្រឡាហូល | | មិនលើសពី១,២ម | ១,២ស.មឡើង | |
| ៤ | ផ្កាក់មឹកសំបកខ្យង | លើសពី១.៥០០ខ្យង | | | |
| ៥ | មងក្តាម | | លើសពី២.០០០ម | ៦ស.មឡើង | |
| ៦ | មងត្រីកាតាំង | | លើសពី២.០០០ម | ៦ស.មឡើង | |
| ៧ | មងត្រីក្បក | | លើសពី២.០០០ម | ៣,៥ស.មឡើង | |
| ៨ | មងត្រីកាម៉ុង | | លើសពី២.០០០ម | ៤ស.មឡើង | |
| ៩ | មងត្រីការ៉ាវ | | លើសពី២.០០០ម | ៧ស.មឡើង | |
| ១០ | មងត្រីបេកា | | លើសពី២.០០០ម | ៨ស.មឡើង | |
| ១១ | មងត្រីស | | លើសពី២.០០០ម | ២ស.មឡើង | |
| ១២ | មងត្រីផ្ទោង | | លើសពី២.០០០ម | ២,៥ស.មឡើង | |
| ១៣ | មងបង្គា៣ជាន់ | | លើសពី២.០០០ម | ៣,៨ស.មឡើង | |
| ១៤ | មងបង្គា១ជាន់ | | លើសពី២.០០០ម | ៣,៥ស.មឡើង | |
| ១៥ | មងហ៊ុម | | លើសពី៥០០ម | ៣ស.មឡើង | |
| ១៦ | លបក្តាម | លើសពី៥០០លប | | ៦ស.មឡើង | |
| ១៧ | លបខ្យង | លើសពី១០០លប | | | |
| ១៨ | លបត្រី | លើសពី៣០លប | | | |
| ១៩ | លបមឹក | លើសពី១០០លប | | ៤ស.មឡើង | |
| ២០ | សន្ទូចបបែល | លើសពី១.៥០០ផ្លែ | | | |
| ២១ | សន្ទូចរនង | លើសពី១.៥០០ផ្លែ | | | |
| ២២ | អួនខូវ ( មងខូវ ) | | លើសពី២០០ម | ៣ស.មឡើង | |
| ២៣ | អួនហ៊ុមកៀនច្រាំង | | លើសពី២០០ម | | |
| ២៤ | អួនទិត និងអួនផ្សេងៗ | | | | |
| ២៥ | អួនអូស | | | ៤ស.មឡើង | |

## ៣-ឧបករណ៍នេសាទឧស្សាហកម្ម

នាវានេសាទដែលមានកម្លាំងលើសពី៥០០សេះ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០១៥

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**ឈឹង ជាសាន**

**បានឃើញ និង យល់ព្រម**

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ឧកញ៉ា វ៉ឹង សាប៊ូន**/៤